

# សារលើខ្សាច់

Let's Read

The Asia Foundation

អ្នកនិពន្ធ  វិចិត្រករ និងអង្គការ CANVAS លើកទឹកចិត្តឲ្យមានការចែករំលែកសៀវភៅ និងបកប្រែអត្ថបទ ប៉ុន្តែយើងរក្សាសិទ្ធិមិនផ្លាស់ប្តូរ រាល់រូបភាពទាំងអស់នៅក្នុងសៀវភៅនេះ។ សូមអរគុណ!



ប៉ូវ៉ារស់នៅក្បែរឆ្នេរសមុទ្រ ហើយគេជាមនុស្សដែលស្រលាញ់សមុទ្រ។





ប៉ុន្តែបូរ៉ាមិនសប្បាយចិត្តពេលឃើញត្រីក្នុងសមុទ្រងាប់
ជាបន្តបន្ទាប់។ ម្តាយរបស់បូរ៉ាបានប្រាប់បូរ៉ាអំពីក្រុមហ៊ុនរុករក
រ៉ែក្នុងស្រុកមួយដែលបង្ហូរកាកសំណាល់ចូលក្នុងទន្លេ ហើយបន្ត
ហូរចូលសមុទ្រ។



"តើនរណាអាចបញ្ឈប់ពួកគេបាន?" បូវ៉ាសួរ ។

"គឺកូន" ម្ដាយឆ្លើយ។

"គឺខ្ញុំ?" បូវ៉ាធ្វើមុខឆ្ងល់

"វាអាស្រ័យលើយើង" ម្ដាយបូវ៉ានិយាយបន្តថា "កូនអាចធ្វើសារ ឱ្យគេបាន។"



ប៉ូវ៉ារើសបានកំណាត់ឈើតូចមួយហើយបានសរសេរអក្សរ
សសយ នៅលើដីខ្សាច់។ សសយ មានន័យថា ”សង្គ្រោះ
សមុទ្រយើង” ប៉ូវ៉ាពន្យល់។



ទឹករលកជោរឡើង ហើយធ្វើឲ្យអក្សរដែលបូរ៉ាបានសរសេររលុបបាត់។



បូរ៉ាសរសេរអក្សរម្តងហើយម្តងទៀត ប៉ុន្តែម្តងនេះគេយក
សារាយសមុទ្រមកផ្គុំជាអក្សរវិញម្តង។



គេដាក់កម្ទេចសំបកខ្យងពីលើ។



ម្ដងហើយម្ដងទៀត ទឹករលកធ្វើឲ្យអក្សរទាំងនោះរលុបបាត់។



”គ្មានប្រយោជន៍ទេ ។ គ្មាននរណាម្នាក់នឹងមើលឃើញសារ
របស់ខ្ញុំទេ ” បូរ៉ាដកដង្ហើមធំ។
 ”ព្យាយាមទៀតទៅកូន ” ម្ដាយរបស់បូរ៉ានិយាយលើកទឹកចិត្ត។
”ចូរកូនបន់ស្រន់ និងមានភាពអត់ធ្មត់។ កុំចុះចាញ់។
ថ្ងៃណាមួយនឹងមាននរណាម្នាក់ឃើញសារនេះ ហើយគ្រប់យ៉ាង
នឹងផ្លាស់ប្ដូរ។”



មិនយូរប៉ុន្មាន មានរថយន្តពណ៌ខ្មៅភ្លឺរលោងស្រិលមួយបាន
បើកមកដល់ផ្ទះរបស់ពួកគេ។ បុរសពីរនាក់ក្នុងសម្លៀកបំពាក់
ជាអ្នកធ្វើការក្រុមហ៊ុន ពាក់វ៉ែនតាខ្មៅចុះពីលើរថយន្តមក។




”រាល់ព្រឹក នៅពេលលោកប្រធានក្រុមហ៊ុនរ៉ែរបស់ពូ ជិះយន្តហោះផ្ទាល់ខ្លួនឆ្លងកាត់ឆ្នេរសមុទ្រ គាត់ឃើញសាររបស់ក្មួយនៅលើដីខ្សាច់។” បុរសម្នាក់និយាយ។

”គាត់បានបញ្ជាឲ្យពូមកទីនេះដើម្បីសួរក្មួយអំពីអត្ថន័យនៃអក្សរ ”ស ស យ” នោះមានន័យយ៉ាងណា?



”ប្រាប់ប្រធានរបស់ពូទៅថាអក្សរ ស ស យ នោះមានន័យថា សង្គ្រោះសមុទ្រយើង” បូរ៉ាឆ្លើយតប។

”ប្រាប់គាត់ឲ្យឈប់បង្ហូរកាកសំណល់ចូលក្នុងទឹកទន្លេទៀត។”



"ព្រោះថាទឹកទន្លេហូរនាំទៅមហាសមុទ្រ។ កាកសំណល់ក្នុងនោះបំពុលត្រីព្រមទាំងរុក្ខជាតិក្នុងទឹក។ វាធ្វើឲ្យទឹក និងឆ្នេរសមុទ្រកខ្វក់។ វាធ្វើឲ្យបក្សាបក្សីឈឺ។ ហើយវាធ្វើឲ្យខ្ញុំមិនសប្បាយចិត្តសោះ។"



បូរ៉ាបន់ស្រន់បួងសួង។ ហើយរៀងរាល់ថ្ងៃបូរ៉ាតែងតែសរសេរអក្សរ
ដដែលៗនៅលើដីខ្សាច់។



ហើយរៀងរាល់ថ្ងៃទឹករលកសមុទ្រជោរឡើង លុបអស់នូវអក្សរ ដែលបូវ៉ាសរសេរទាំងប៉ុន្មាន។



ថ្ងៃមួយ ម្ដាយរបស់បូរ៉ាបានបង្ហាញចំណងជើងកាសែតមួយ
ដែលសរសេរថា៖ ”ក្រុមហ៊ុនរ៉ែទទួលបានដំណឹង ឱ្យបញ្ឈប់ការ
ចោលកាកសំណល់ចូលក្នុងសមុទ្រ។”




ប៉ូរ៉ា រត់ទៅឆ្នេរសមុទ្រទាំងញញឹម ហើយគេបានយក
កំណាត់ឈើមកសរសេរពាក្យថ្មីមួយទៀតនៅលើដីខ្សាច់ថា "
អរគុណ" ។



ទឹកសមុទ្រជោរឡើង លុបពាក្យរបស់ប៉ូវ៉ា។ វាហូរនាំយកពាក្យ
ទាំងនោះទៅកន្លែងដែលឆ្ងាយសែនឆ្ងាយ។

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*Message in the Sand*, Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by/4.0/
Contributing translators: Somey Chheang, Runny Vong, and Chou Chinith